**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ២៥...០២៦...០៧០...ប្រ.ក...

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញា
## សម្រាប់ប្រព័ន្ធទូទាត់សងប្រាក់រួម (Integrated Payment System – IPS)

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការតែងតាំង **លោកជំទាវ ជា សិរី** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជានិងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពី ការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១៥-០២៦-០៥៣ ប្រ.ក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥ ស្តីពី ការដាក់ឱ្យប្រើវិធាន និងនីតិវិធីប្រព័ន្ធទូទាត់សងប្រាក់រួម
- យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់ស្លាកសញ្ញារបស់ប្រព័ន្ធទូទាត់សងប្រាក់រួម (Integrated Payment System – IPS) សម្រាប់ជាសញ្ញាសម្គាល់ផ្លូវការប្រើប្រាស់នៅក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅរក្សាសង្គតិភាពក្នុងការប្រើប្រាស់ស្លាកសញ្ញា "IPS" ជាសាធារណៈ ធានាពីសិទ្ធិនិងប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធ និងការពារផលប្រយោជន៍របស់គ្រឹះស្ថានជាសមាជិកប្រព័ន្ធទូទាត់សងប្រាក់រួម។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករពាក់ព័ន្ធដែលចូលរួមក្នុងប្រព័ន្ធទូទាត់សងប្រាក់រួម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកនៃប្រព័ន្ធទូទាត់សងប្រាក់រួម ត្រូវរៀបចំបោះពុម្ព និងប្រើប្រាស់ស្លាកសញ្ញាឱ្យបានត្រឹមត្រូវនិងមានលក្ខណៈស្តង់ដា ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៥.-**

រាល់ការក្លែងបន្លំ ការប្រើប្រាស់ស្លាកសញ្ញាមិនត្រឹមត្រូវ និង/ឬការប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជានឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ ៦.-**

អគ្គលេខាធិការ អគ្គនាយកប្រតិបត្តិការ អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ អគ្គបេឡា អគ្គនាយកគ្រប់គ្រងសាច់ប្រាក់ អគ្គពិនិត្យ ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិករបស់ប្រព័ន្ធទូទាត់សងប្រាក់រួម ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៣ រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មករា ឆ្នាំ២០២៦

**ទេសាភិបាល**

**ជា សិរី**

**កន្លែងទទួល ៖**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"
- ដូចប្រការ ៦
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ
# លក្ខណៈសម្គាល់ស្លាកសញ្ញា
# ប្រព័ន្ធទូទាត់សងប្រាក់រួម (Integrated Payment System – IPS)

ធនាគារជាតិនៃកម្ពុជា សូមណែនាំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអំពីការរៀបចំទ្រង់ទ្រាយ សណ្ឋាន និងពណ៌របស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់រួម “IPS” ដូចខាងក្រោម៖

## ១. លក្ខណៈសម្គាល់

ស្លាកសញ្ញាប្រព័ន្ធទូទាត់សងប្រាក់រួម “IPS” មានរាងជាបញ្ចកោណមានឆ្នូតសចំនួន ២ នៅខាងក្នុងដែលតំណាងឱ្យនវានុវត្តន៍ឌីជីថល។ រាងជាបញ្ចកោណសរុបមានចំនួន ៨ ផ្គុំជារង្វង់ ក្នុងនោះមានពណ៌ក្រហមចំនួន ៤ ពណ៌ខៀវចំនួន ៤ ហើយមានស្លាកសញ្ញាប្រព័ន្ធបាគងដែលជាប្រព័ន្ធចម្បងនៅចំកណ្តាល។ នៅខាងក្រៅរង្វង់ មានអក្សរឡាតាំង “IPS” ពណ៌ខ្មៅនៅខាងក្រោម ដែលជាអក្សរកាត់តំណាងឱ្យប្រព័ន្ធទូទាត់សងប្រាក់រួម (Integrated Payment System – IPS)។

## ២. ទម្រង់នៃស្លាកសញ្ញា

ស្លាកសញ្ញាប្រព័ន្ធទូទាត់សងប្រាក់រួម “IPS” នឹងត្រូវពង្រីក ឬបង្រួមទំហំតាមសមាមាត្រទម្រង់របស់ស្លាកសញ្ញាដែលបានកំណត់ប្រវែងទទឹងស្មើនឹង x និងប្រវែងបណ្តោយស្មើនឹង x។

## ៣. ពណ៌នៃស្លាកសញ្ញា

ពណ៌នៃស្លាកសញ្ញានេះគឺពណ៌ក្រហម ខៀវ ស និងខ្មៅ ដែលមានពណ៌គោលដូចខាងក្រោម៖

- **ពណ៌ក្រហម** **R: 228 G: 31 B:38**
- **ពណ៌ខៀវ** **R: 24 G: 44 B: 192**
- **ពណ៌ស** **R: 255 G: 255 B: 255**
- **ពណ៌ខ្មៅ** **R: 0 G: 0 B: 0**

## ៤. ការប្រើប្រាស់ស្លាកសញ្ញា

គ្រឹះស្ថានជាសមាជិកត្រូវបិទស្លាកសញ្ញាប្រព័ន្ធទូទាត់សងប្រាក់រូម "IPS" ដូចបានកំណត់ខាងលើ នៅតាមទីតាំងដែលងាយកត់សម្គាល់។

សម្រាប់ព័ត៌មានលម្អិតអំពីស្លាកសញ្ញាប្រព័ន្ធទូទាត់សងប្រាក់រូម "IPS" នឹងមានចែងក្នុងសៀវភៅណែនាំដោយឡែក។